ចក្ខុមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ខចារណកថាព័ត៌មានរបស់ ម.ស.ម.ក

ភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២

## ម.ស.ម.ក លើកឡើងពីបញ្ញត្តច្បាប់ថ្មីមួយរបស់ប្រទេសចិន ដែលបង្ហាមិនឲ្យមានការរំលោភយកដីធ្លី និងអំពាវនាវឲ្យកម្ពុជាគួរយកគំរូតាម

ប្រទេសចិនដែលជាសម្ព័ន្ធមិត្តដ៏យូរលង់ណាស់មកហើយរបស់ប្រទេសកម្ពុជា កំពុងតែបន្តពុះពារតាក់តែងច្បាប់មួយដែលមានគោលបំណងការពារកុំឲ្យមានការទន្ទ្រានយកដីធ្លីដ៏ចំរូងចំរាស់និងដោយរំលោភ ដែលជាកិច្ចប្រឹងប្រែងមួយរបស់ប្រទេសចិន ក្នុងការលុបបំបាត់នូវចលាចលសង្គមដែលកំពុងតែមានការកើនឡើងក្នុងប្រទេស។ នេះបើតាមសេចក្តីរាយការណ៍មួយចុះផ្សាយលើអត្ថបទកាសែត **ខេមបូឌាដេលី** ដែលមានចំណងជើងថា(‵ប្រទេសចិនប្រយុទ្ធប្រឆាំងការរំលោភយកដីធ្លីដែលនាំឲ្យមានកំហឹងដល់ប្រជាជនរស់នៅតាមជនបទ′ ចុះផ្សាយនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ ទំ.២២)។ នៅក្នុងសប្តាហ៍ជាមួយគ្នានេះ មានរបាយការណ៍មួយត្រូវបានចុះផ្សាយដោយអង្គការចំនួន៣ របស់ប្រទេសស៊ុយអែត ដែលបានលើកយកប្រទេសកម្ពុជា ជាករណីសិក្សាមួយក្នុងចំណោមករណីសិក្សាពីរស្តីពីផលប៉ះពាល់អវិជ្ជមានលើការរំលោភបំពានដីធ្លី និងលោកនាយករដ្ឋមន្ត្រីជិតផុតអាណត្តិរបស់ប្រទេសចិន វេន ជាបាវ កំពុងតែផ្តល់ការយកចិត្តទុកដាក់ជាខ្លាំង ចំពោះការធ្វើវិសោធនកម្មច្បាប់គ្រប់គ្រងកម្មសិទ្ធិដីធ្លី ដែលនឹងធ្វើឲ្យមានភាពកាន់តែលំបាកឡើងដល់មន្ត្រីមូលដ្ឋានដើម្បីទាមទាយកដីមកវិញ និងបង្កើននូវកម្រិតនៃសំណងជូនដល់ប្រជាកសិករ ដែលដីរបស់ពួកគាត់ត្រូវបានដកហូតដើម្បីផលប្រយោជន៍សាធារណៈ[1]។ គេមើលឃើញថា មានចលាចលពលរដ្ឋកំពុងតែកើតមានឡើងប្រឆាំងចំពោះការរឹបអូសដីធ្លីនៅតាមជនបទក្នុងប្រទេសចិន ដែលមាន ៦៥ ភាគរយនៃចលាចលសង្គមនេះត្រូវគេលើកឡើងថាជាការបណ្តាលមកពីបញ្ហាជម្លោះដីធ្លី[២]។

---

[១] ប្រទេសចិនប្រយុទ្ធប្រឆាំងការរំលោភដីធ្លី បណ្តាលឲ្យផ្ទុះកំហឹងដល់ពលរដ្ឋតាមជនបទ ចុះផ្សាយលើកាសែត ដឹ ខេមបូឌាដេលី ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០១២។

[២] ចុះផ្សាយលើកាសែត អាយប៊ិត

[៣] របាយការណ៍ ស្តីពីការរំលោភយកដីទូទាំងពិភពលោក ចុះផ្សាយលើកាសែត ខេមបូឌាដេលី នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១២

ភាពចលាចលសង្គម ដែលកំពុងកើនឡើងពីសំណាក់ពលរដ្ឋក្នុងប្រទេសចិននាពេលបច្ចុប្បន្ន ក៏បានឆ្លុះបញ្ចាំងពីទិដ្ឋភាពមួយក្នុងប្រទេសកម្ពុជាទាក់ទងនឹងការរំលោភយកដីធ្លី នឹងការបណ្តេញចេញដោយបង្ខំ។

សេចក្តីអាត្ថាធិប្បាយលើអត្ថបទ ឌឺ រ៉េស ហ្វ៎ ឡេន(“របាយការណ៍”)ចេញផ្សាយរួមគ្នាកាលពីសប្តាហ៍មុន ដោយអង្គការមិនមែនរដ្ឋាភិបាលរបស់ប្រទេសស៊ុយអែតគឺអង្គការ ការិន គ្រីគូ ហ្វ៊ូរ៉ុម ស៊ីដ ថ្លែងថាប្រទេសកម្ពុជា “គឺជាឧទាហរណ៍យ៉ាងច្បាស់មួយពីផលប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរក្នុងការរំលោភយកដីធ្លី” និងករណីរិបអូសយកដីធ្លីនៅទូទាំងពិភពលោកដែលត្រូវបានឃ្លាំមើលដោយអង្គការមួយនេះមួយនេះ និងបានពិពណ៌នាថាកម្ពុជា “ជាប្រទេសមួយដែលមានការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ[៣]”។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ជម្រុញឲ្យរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់ពិចារណាឡើងវិញនូវក្តីព្រួយបារម្ភដែលបានលើកឡើងក្នុងរបាយការណ៍នេះ ហើយអនុម័តនូវច្បាប់មួយស្រដៀងគ្នា នឹងច្បាប់ថ្មីដែលបច្ចុប្បន្នកំពុងត្រូវបានពិចារណាដោយក្រុមប្រឹក្សាជាតិរបស់ប្រទេសចិន។ បើពុំមានច្បាប់បែបនេះទេនោះ សិទ្ធិមូលដ្ឋាននៃជនដែលទទួលផលប៉ះពាល់ដោយសារបញ្ហាដីធ្លី នៅតែមិនត្រូវបានការពារគ្រប់ជ្រុងជ្រោយ ហើយឧប្បទវហេតុនៃចលាចលពលរដ្ឋ ទំនងនឹងនៅតែបន្តកើតមានឡើង។ ថ្វីបើមានការប្រកាសផ្អាកជាបណ្តោះអាសន្នក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច តែគេសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះដដែល ហើយអាជ្ញាធរបានចាប់ប្រជាពលរដ្ឋជាច្រើននាក់ ដែលប្រឆាំងតវ៉ានឹងការផ្តល់ ដីសម្បទានសេដ្ឋកិច្ចក្នុងឆ្នាំនេះ។ ម.ស.ម.ក អំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ធ្វើឲ្យមានតម្លាភាពកាន់តែប្រសើរឡើងចំពោះចំនួនដីសម្បទានសេដ្ឋកិច្ចដែលបានផ្តល់ឲ្យក្រុមហ៊ុន មុនការប្រកាសផ្អាកជាបណ្តោះអាសន្ននេះចូលជាធរមាន និងសូមធ្វើវិសោធនកម្មនូវច្បាប់ដែលមានស្រាប់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ពលរដ្ឋកម្ពុជាទូទៅ។

**លោក វណ្ណ សផាត មន្រ្តីសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក មានមតិថា៖**

*“ហេតុដែលរដ្ឋាភិបាលចិនកំពុងខិតខំអនុម័តនូវច្បាប់ថ្មីនេះ គឺដើម្បីការពារសិទ្ធិពលរដ្ឋរបស់ខ្លួននិងដើម្បីធានាថា ពលរដ្ឋត្រូវគេផ្តល់នូវសំណងសមរម្យ ក្នុងករណីដែលដីរបស់ពួកគាត់ត្រូវបានដកហូត ដែលបង្ហាញពីភាពធ្ងន់ធ្ងរកើតឡើងពីការរំលោភយកដីធ្លី និងផលប៉ះពាល់នានាដែលអាចនាំឲ្យមានចលាចលពលរដ្ឋក្នុងសង្គម។ បន្ទាប់ពីរបាយការណ៍ចេញផ្សាយដោយក្រុមអង្គការរបស់ប្រទេសស៊ុយអែត ម.ស.ម.ក សង្ឃឹមថា រាជរដ្ឋាភិបាលកម្ពុជា នឹងយកគំរូស្រដៀងគ្នាទៅនឹងរដ្ឋាភិបាលចិន ដើម្បីធានាថាពលរដ្ឋដែលទទួលរងផលប៉ះពាល់ដោយដីសម្ប-ទានសេដ្ឋកិច្ច ត្រូវបានដោះស្រាយដោយយុត្តិធម៌។”*

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក វណ្ណ សុផាត មន្ត្រីសម្របសម្រួលកម្មវិធីកំណែទម្រង់ដីធ្លី (+៨៥៥ (0) ១២ ៩៤១ ២០៦ ឬអ៊ីម៉ែល៖ vann.sophath@cchrcambodia.org ឬ លោក រ៉ូប៊ឺត ហ្វីញ ទីប្រឹក្សាជាន់ខ្ពស់ (+៨៥៥ (0) ៧៨ ៨០៩ ៩៦០ ឬអ៊ីម៉ែល៖ robert.finch@cchrcambodia .org)

ព័ត៌មានបណ្ណាធិការ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងនយោបាយនៅកម្ពុជា ។

ម.ស.ម.ក គឺជាសមាជិកដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិអន្តរជាតិ (IFEX) បណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ ២០១២ ស្ថិតនៅក្នុងប្រភេទ "សិទ្ធិ និង សេរីភាព" ។